Jack M. Weiss

ឧត្តមមន្ត្រី

នៃមជ្ឈមណ្ឌលច្បាប់នៃសាកលវិទ្យាល័យ LSU Paul M. Hebert

នៅឯ Baton Rouge រដ្ឋ Louisiana 70803

លោក Jack M. Weiss ជាអាជ្ញាធរច្បាប់សារពត៌មានជាតិ និងមានកំណើតនៅក្នុងរដ្ឋ Louisiana
ត្រូវបានគេតែងតាំងជាឧត្តមមន្ត្រីនិងជាសាស្ត្រាចារ្យផ្នែកច្បាប់នៅឯមជ្ឈមណ្ឌលច្បាប់នៃសាកលវិទ្យាល័យ LSU Paul M. Hebert នៅខែឧសភា ឆ្នាំ2007។

កំឡុងពេលកាន់តំណែងជាឧត្តមមន្ត្រីរបស់លោក Weiss
សាកលវិទ្យាល័យបានធ្វើការពង្រីកយ៉ាងសម្បើមនូវវិស័យអប់រំ
ច្បាប់មូលដ្ឋានរបស់ខ្លួន និងកម្មវិធីខាងក្រៅ ហើយបានជ្រើសរើសគ្រូមហាវិទ្យាល័យថ្មីៗ
ប្រកបដោយជំនាញជ្រៅជ្រះ
ចំនួនដប់ពីរនាក់ បានលើកកំពស់នូវភាពសមត្ថភាពរបស់និស្សិត
បានពិនិត្យមើលយ៉ាងត្រឹមត្រូវនូវឯកសារសិក្សារបស់ខ្លួន និង
គោលនយោបាយអប់រំនិស្សិត
និងបានសម្ពោធអោយមានកម្មវិធីអាហារូបករណ៍សម្រាប់គ្រូបង្រៀនផ្នែកច្បាប់ដែលមានសក្តានុពលនាពេល
អនាគត។

មុនពេលក្លាយជាឧត្តមមន្ត្រី លោក Weiss
គឺជាអ្នកការពារចុងចោទខាងផ្នែកសិទ្ធិអ្នកសារព័ត៌មានសេរីភាពឈានមុខគេថ្នាក់ជាតិម្នាក់ក្នុងចំណោមអ្នកការពារចុងចោទដ៏ទៃទៀតអស់រយៈពេលជាច្រើនឆ្នាំ។
ក្រៅពីកាតព្វកិច្ចជាឧត្តមមន្ត្រីនេះ លោក Weiss

បង្រៀនមុខវិជ្ជាសិទ្ធិដែលមានចែងនៅក្នុងមាត្រាច្បាប់ស្តីពីវិញ្ញាត្តិ និងសមាគមន៍ច្បាប់សារព័ត៌មាន និងវគ្គសិក្សាខ្លីៗទៀត។

លោក Weiss បានបញ្ចប់ការសិក្សាខាងផ្នែក Phi Beta Kappa និង cum laude នៅឯសាកលវិទ្យាល័យ Yale ក្នុងឆ្នាំ1968 និងផ្នែក magna cum laude នៅឯសាលាច្បាប់ Harvard ក្នុងឆ្នាំ1971 ជាកន្លែងដែលគាត់ធ្វើជាហេរញ្ញិក និងជាអ្នកកែសម្រួល ក្នុងការគ្រប់គ្រងពិនិត្យមើលផ្នែកច្បាប់នៅក្នុងសាលា Harvard។ ការបញ្ចប់ការសិក្សាបន្តបន្ទាប់មកទៀត នៅឆ្នាំ1971-72 លោក Weiss បានបម្រើការងារជាក្រឡាបញ្ជីសម្រាប់ តុលាការនៃអង្គចៅក្រមបណ្តឹងឧទ្ធរណ៍របស់ John Minor Wisdom ជុំទីប្រាំនៅក្នុងសហរដ្ឋអាមេរិក បន្ទាប់មកនៅឆ្នាំ 1972-73 បានបម្រើការងារជាក្រឡាបញ្ជីជាន់ខ្ពស់សម្រាប់ប្រធានអង្គចៅក្រម Warren E. Burger។

លោក Weiss បានទៅបម្រើការងារជាជំនួយការផ្នែកច្បាប់សម្រាប់សមាជិកព្រឹទ្ធសភានៃសហរដ្ឋអាមេរិក J. Bennett Johnston។ គាត់បានបំពេញការងារផ្នែកច្បាប់នៅក្នុងក្រុង New Orleans អស់រយៈកាល 23 ឆ្នាំមុននឹងផ្លាស់ទៅក្រុង New York នៅឆ្នាំ 1998 ដើម្បីធ្វើជាដៃគូជាមួយ Gibson Dunn និង Crutcher។ នៅទីក្រុង New York លោក Weiss បានបន្តការងាររបស់គាត់តំណាងអោយផ្នែកសារព័ត៌មានជាតិ ដែលគួរអោយកត់សំគាល់ភាគច្រើនគឺក្រុមហ៊ុន Dow Jones & Company, Inc. ជាក្រុមហ៊ុនបោះពុម្ពផ្សាយសារព័ត៌មាន The Wall Street Journal។

ក្នុងកំឡុងអជីពការងារដ៏យូររបស់គាត់នៅក្នុងរដ្ឋ Louisiana លោក Weiss គឺជាមេធាវីក្រៅប្រព័ន្ធសម្រាប់សារព័ត៌មាន Times-Picayune នៃក្រុង New Orleans និងបានធ្វើជាតំណាងសារព័ត៌មាននៃរដ្ឋ Louisiana ជាច្រើនផ្សេងទៀត និងអង្គការ

សារព័ត៌ជាតិក្នុងតំបន់។ ក្នុងរយៈពេលច្រើនឆ្នាំនៃការបំពេញការងារនៅឯទីក្រុង New York លោក Weiss បាន
សម្តែងការមិនសមរម្យក្នុងរង្វង់មេធាវីសារព័ត៌មានធំៗប្រចាំក្រុង។

ក្រៅពីការផ្តល់សេវាកម្មរដ្ឋាភិបាលរបស់គាត់ និងបទពិសោធន៍ជាគណៈមេធាវីកាត់ក្តី លោក Weiss
យកជំនាញមូលដ្ឋានខាងបណ្ឌិតសភាដ៏ពូកែរបស់គាត់មកបម្រើនៅក្នុងភាពជាឧត្តមមន្ត្រី។ តាំងពីឆ្នាំ1980 រហូតដល់ការឈានជើងត្រលប់មក
មជ្ឈមណ្ឌលច្បាប់នៃសាកលវិទ្យាល័យ LSU របស់គាត់ក្នុងឆ្នាំ2007 លោក Weiss បានធ្វើការបង្រៀនរហូត
ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំធ្វើជាសមាជិកបន្ទាប់បន្សំនៃមហាវិទ្យាល័យក្នុង
សាលាច្បាប់ Columbia Tulane និង LSU។

ឧត្តមមន្ត្រី Weiss គឺជាជនទីដប់តែម្នាក់គត់ដែលបានចុះឈ្មោះនៅក្នុងប្រវត្តិសាស្រ្ត 104 ឆ្នាំរបស់មជ្ឈមណ្ឌលច្បាប់ក្នុងតួនាទីការងារជាព្រឹទ្ធបុរស ឬឧត្តមមន្ត្រី។